[redacted] 012643333 71/5

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

479

23-3-2020

សាលាដំបូងខេត្តកំពង់ចាម

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តកំពង់ចាម

សាលក្រមព្រហ្មទណ្ឌ

លេខ ៩១ ( ច ) ✓

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០

សំណុំរឿងព្រហ្មទណ្ឌលេខ ៤២១

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩

សំណុំរឿងស៊ើបសួរលេខ ៣៥០

ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩

សំណុំរឿងជំនុំជំរះលេខ ៧២៤

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង៩ព្រឹក ដោយមានសមាសភាពដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

លោក [redacted]ចៅក្រមប្រឹក្សា ។

លោក [redacted] ចៅក្រមប្រឹក្សា ។

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ចាម ។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៤២១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖ ឈ្មោះ [redacted] ស៊ុល ហៅហ្សុល ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរឥស្លាម សាសនាឥស្លាម ទីកន្លែងកំណើតភូ [redacted] ខេត្តកំពង់ចាម មុខរបរលក់សាច់គោ ទីលំនៅសព្វថ្ងៃភូមិរកាក្រោម សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] សេត "រ" ម្តាយឈ្មោះ [redacted] សំ "រ" ប្រពន្ធឈ្មោះ [redacted] ហាស្នា មានកូន១នាក់ ទោសពីមុនគ្មាន ។

ឃុំខ្លួនថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨១៨ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ។

មានមេធាវីលោកតែ [redacted] ។

ជាប់ចោទពីបទ ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង១៨ និង៣០នាទី សមត្ថកិច្ចបានទទួលពត៌មានពីប្រជាពលរដ្ឋរាយការណ៍មកថា ៖ មានជនសង្ស័យម្នាក់យកស្បោងច្រកប្រអប់បួនជ្រុងទៅផ្ញើតាមរថយន្តតាក់ស៊ីនៅចំណុចភូមិទី៨ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។ បន្ទាប់មកសមត្ថកិច្ចបានចុះទៅដល់គោលដៅ និង បានកំណត់មុខសញ្ញាហើយឈានទៅឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ ទី១ឈ្មោះ [redacted] ស៊ុល ហៅហ្សុល ភេទប្រុស អាយុ២៥ឆ្នាំ ដោយបានឆែកឆេរនៅក្នុងផ្ទះជួលឃើញមានម៉ៅក្រាមពណ៌ស ចំនួន០៣កញ្ចប់ ជញ្ជីងអេឡិចត្រូនិចចំនួន០១គ្រឿង ទូរស័ព្ទម៉ាកចុចពិល០១គ្រឿង សម្ភារៈប្រើប្រាស់ និង ថង់ផ្លាស្ទិចខ្ចប់មួយចំនួន និង ទី២ឈ្មោះ [redacted] អាល់ហ្វីន ភេទប្រុស អាយុ១៧ឆ្នាំ ដោយដកបានទូរស័ព្ទ០១គ្រឿង ។ តែឈ្មោះ [redacted] អាល់ហ្វីន នេះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យខេត្តកំពង់ចាម៖

Scanned with CamScanner

ដើម្បីធ្វើការបន្សាបគ្រឿងញៀនហើយ ។

-បានឃើញ របាយការណ៍សំយោគលេខ៣៤ / ២០១៩ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់បញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ចាម ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៥៩៧ / អ.យ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

-បានឃើញ ដីកាដំណោះស្រាយលេខ១៦០១ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ៨០១ / ចត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម ។

## **នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ[redacted] ស៊ុល ហៅហ្សុល បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៨ព្រឹក ខ្លួនបានយកថ្នាំញៀន០១កញ្ចប់តូចដែលខ្លួនបានទិញពីឈ្មោះធឿន នៅស្រុកស្ទឹងត្រង់ ទៅផ្ញើតាមរថយន្តតាក់ស៊ីអោយមិត្តភក្តិរបស់ខ្លួនឈ្មោះនី នៅខេត្តព្រះវិហារ ។ លុះដល់ម៉ោង៩ព្រឹក ខ្លួនកំពុងអង្គុយហូបបបរនៅក្នុងបន្ទប់ជួលជាមួយឈ្មោះ[redacted] អាល់ហ្វីន ស្រាប់តែសមត្ថកិច្ចចូលមកចាប់រូបខ្លួនហើយបានឆែកឆេរឃើញ ថ្នាំញៀនចំនួន០៣កញ្ចប់ធំ ជញ្ជីងអេឡិចត្រូនិចចំនួន០១គ្រឿង និង សម្ភារៈប្រើប្រាស់ថ្នាំញៀនមួយសម្រាប់ ។ ថ្នាំញៀននេះឈ្មោះ[redacted] នៅស្រុកស្ទឹងត្រង់ផ្ញើមកអោយខ្លួនរក្សាទុកឲ្យ ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ទោះបីជនជាប់ចោទឈ្មោះ[redacted] ស៊ុល បដិសេធក៏មិនមាចមោឃៈភាពនីតិវិធីស៊ើបសួរបានទេ ។ តម្កល់ការចោទប្រកាន់របស់ខ្លួនទុកនៅដដែល ។

មេធាវីការពារសិទ្ធិអោយជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា ៖ ថ្នាំញៀនដែលសមត្ថកិច្ចរកឃើញនៅក្នុងផ្ទះដែលកូនក្តីខ្ញុំស្នាក់នៅ មិនមែនជាថ្នាំញៀនរបស់កូនក្តីខ្ញុំទេ គឺជាថ្នាំញៀនដែលគេផ្ញើអោយកូនក្តីខ្ញុំទុកហើយកូនក្តីខ្ញុំក៏មិនបានដឹងថារបស់ផ្ញើនេះជាថ្នាំញៀនដែរ ។ ចំពោះវត្ថុតាងថ្នាំញៀនដែលកូនក្តីខ្ញុំទទួលស្គាល់ថាជារបស់ខ្លួនមានត្រឹមតែ០១កញ្ចប់តូចតែប៉ុណ្ណោះ ដូច្នេះខ្ញុំស្នើសុំអោយលោកចៅក្រមពិចារណាអំពីវត្ថុតាងដាក់បន្ទុកលើកូនក្តីខ្ញុំមានថ្នាំញៀន០១កញ្ចប់តូច ហើយសុំអោយផ្តន្ទាទោសកូនក្តីខ្ញុំក្នុងកំរិតទាបបំផុត ។

-ជនជាប់ចោទឈ្មោះ[redacted] ស៊ុល បាននិយាយសំដីចុងក្រោយថា សុំអោយតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted] ស៊ុល ។

-ក្រោយពីបានស្តាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ[redacted] ស៊ុល ។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានាត្រឹមត្រូវហើយ ។

-ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## **យល់ឃើញថា**

១-តាមដីកាបញ្ជូនសំណុំរឿងមកជំនុំជម្រះជនជាប់ចោទឈ្មោះ[redacted] ស៊ុល ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរឥស្លាម ដាក់ក្រោមការពិនិត្យពីបទ ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-សំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុល សុំអោយតុលាការបន្ធូរបន្ថយទោស ។ តប្បីតុលាការមិនពិចារណាលើសំណូមពរនេះទេ ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ុល ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរឥស្លាម សម្រេចដាក់ពន្ធនាគារកំណត់រយៈពេល១៣ឆ្នាំ ( ដប់បីឆ្នាំ ) ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៤០នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-សម្រេចរឹបអូសវត្ថុតាងរួមតាមកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ុល បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |
| | ហត្ថលេខា និងត្រា [redacted] | |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ០១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កំពង់ចាម ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
ថ្ងៃសុក្រ ០១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
កំពង់ចាម ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**
[redacted]

Scanned with CamScanner